ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 24-Apr-2020, 09:20
CMS/CFO: Sann Rada

**អង្គជំនុំជម្រះតុលាការកំពូល**
Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Maureen Harding CLARK**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២០**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

---

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមទំព័រសារណាតបទៅ នឹងសារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០២

---

**សហព្រះរាជអាជ្ញា**

ជា លាង
Brenda HOLLIS

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Megan HIRST

**ជនជាប់ចោទ**

ខៀវ សំផន

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" ឬ"អង្គជំនុំជម្រះ" និង"អ.វ.ត.ក") បានទទួលសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រ ដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០២ ("សំណើសុំរបស់សហព្រះរាជអាជ្ញា" ឬ "សំណើសុំ")[1] ដែលបានដាក់នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២០។

## ក. សាវតារ

1. នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសេចក្តីសង្ខេបនៃការយល់ឃើញរបស់ខ្លួន និងផ្នែកសម្រេចសេចក្តីពាក់ព័ន្ធទៅនឹងការទទួលខុសត្រូវ និងទោសរបស់ជនជាប់ចោទ ក្នុងសំណុំរឿង ០០២/០២ និងនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ អង្គជំនុំជម្រះសាលាដំបូងចេញសាលក្រមដែលមានសំអាងហេតុពេញលេញ[2]។

2. នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន[3] និងនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៩ ខៀវ សំផន បានស្នើសុំបន្ថែមពេលវេលាដប់ខែកន្លះ និងទំព័រ(៩៥០ ទំព័រ) សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ[4]។ នៅថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញាបានដាក់សំណើសុំឱ្យអង្គជំនុំជម្រះផ្តល់ពេលវេលា និងចំនួនទំព័រដូចគ្នាទៅនឹងការផ្តល់ឱ្យទៅខៀវ សំផន[5]។

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមទំព័រដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន នៃសាលក្រមក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២០ ឯកសារលេខ F55 ("សំណើរបស់សហព្រះរាជអាជ្ញា" ឬ"សំណើសុំ")។

[2] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ **E465** ("សាលក្រម")។

[3] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន (002/02) ឯកសារលេខ **E65/4/1** ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩។

[4] សំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ឯកសារលេខ **F45** ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៩។

[5] សំណើរបស់សហព្រះរាជអាជ្ញាសុំកែប្រែទៅនឹងលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់សារណាតបទៅនឹងបណ្តឹងសាទុក្ខ ឯកសារលេខ **F48** ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៩។

3. នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ឱ្យ ខៀវ សំផន នូវពេលវេលាបន្ថែម ក្នុងការដាក់សារណារបស់ខ្លួនមិនឱ្យលើស ៧៥០ ទំព័រ និងបានណែនាំសហព្រះរាជអាជ្ញាឱ្យដាក់សារណាតបមិនឱ្យលើស ៣៥០ ទំព័រ[6]។

4. នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០ ខៀវ សំផន បានដាក់សារណាបណ្តឹងសាទុក្ខ(“សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន”) ជាភាសាបារាំង[7]។

5. នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាបានដាក់សំណើសុំរបស់ខ្លួន។ ខៀវ សំផន បានដាក់សារណាតបទៅនឹងសំណើសុំនេះនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២០ (“សារណាតបរបស់ ខៀវ សំផន” ឬ“សារណាតប”)[8]។ នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២០ សហព្រះរាជអាជ្ញាបានដាក់ការឆ្លើយតបទៅនឹងសារណាតប[9]។

## ២. សារណា

*សំណើរបស់សហព្រះរាជអាជ្ញា*

6. សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះអនុញ្ញាតបន្ថែម ១៤៥ ទំព័រ ដើម្បីឱ្យខ្លួនអាចឆ្លើយតបគ្រប់គ្រាន់ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន និងបានលើកឡើងថា សារណាចំនួន ៧៥០ ទំព័ររបស់ ខៀវ សំផន បានភ្ជាប់មកជាមួយនូវឧបសម្ព័ន្ធ(“ឧបសម្ព័ន្ធ ក”) ដែលមានចំនួន ៧៦ ទំព័រ និងការយោងទៅលើសារណាមុនៗយ៉ាងតិច ២៣៦ ទំព័រ ដែលនេះជាការពង្រីកខ្លឹមសារនៃសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ហើយដើម្បីអាចឆ្លើយតបបានដោយប្រសិទ្ធភាព តម្រូវឱ្យមានចំនួនទំព័របន្ថែម[10]។

---

[6] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ឯកសារលេខ **F49** ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩។

[7] សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ឯកសារលេខ **F54** ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២០។

[8] សារណាតបរបស់ ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រដើម្បីឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០២ ឯកសារលេខ **F55/1** ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២០ (“សារណាតបរបស់ ខៀវ សំផន”)។

[9] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាតបរបស់ ខៀវ សំផន ទៅនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០២ ឯកសារលេខ **F55/2** ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០២០ (“ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា”)។

[10] សំណើសុំរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១, ៨, ១០ ដល់ ១១។

7. សហព្រះរាជអាជ្ញាបានអះអាងថា ឧបសម្ព័ន្ធ ក ដែលមានចំណងជើងថា "សេចក្ដីសង្ខេបទឡ្ហីករណ៍បណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) ជាមួយនឹងការកំណត់អត្តសញ្ញាណនៃកំហុសនៅក្នុងសារណាបណ្ដឹងសាទុក្ខ" មានសារៈសំខាន់ទាំងមូលលើសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ដោយសារបានផ្ដល់ទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ ដែលត្រូវបានគាំទ្រដោយអំណះអំណាងនៅក្នុងនោះ។ សហព្រះរាជអាជ្ញាបានជំទាស់ថា ឧបសម្ព័ន្ធ ក ត្រូវបានបន្ថែមចូលដោយ ខៀវ សំផន ដើម្បីជួសជុលភាពខុសគ្នារវាងសារណាបណ្ដឹងសាទុក្ខជាមួយនឹងសេចក្ដីជូនដំណឹង និងថា ឧបសម្ព័ន្ធ ក បានកំណត់អត្តសញ្ញាណ និងផ្ដោតជាពិសេសអំពីទឡ្ហីករណ៍នៃបណ្ដឹងសាទុក្ខ ផ្នែកនានាក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូងដែលត្រូវប្ដឹងសាទុក្ខ កំហុសដែលបានចោទប្រកាន់ និងសិទ្ធិដែលត្រូវបានរំលោភបំពាន និងផលវិបាកនៃការរំលោភបំពានទាំងអស់នេះ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាបានលើកឡើងថា ឧបសម្ព័ន្ធ ក មានភាពចាំបាច់ចំពោះអង្គជំនុំជម្រះ និងភាគីជំទាស់ ដើម្បីអាចកំណត់អត្តសញ្ញាណនៃទឡ្ហីករណ៍បណ្ដឹងសាទុក្ខ និងបង្ហាញ ថាតើបំពេញតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្ដឹងសាទុក្ខ ដែរ ឬយ៉ាងណា[11]។

8. សហព្រះរាជអាជ្ញាបានកត់សម្គាល់បន្ថែមថា ខៀវ សំផន បានបញ្ចូលតាមរយៈការយោងទៅលើអំណះអំណាងពីមុនៗយ៉ាងតិចចំនួន ២៣៦ ទំព័រពីសារណាបណ្ដឹងសាទុក្ខរបស់ខ្លួនក្នុងសំណុំរឿង ០០២/០១ និងសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ ដោយជៀសវាងការលើកច្រំដែល[12]។ សហព្រះរាជអាជ្ញាបានជំទាស់ថា សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន បច្ចុប្បន្នសរុប ១ ០៦២ ទំព័រ ដែលលើសយ៉ាងតិច ៣១២ ទំព័រ ហួសពីការកំណត់ចំនួនទំព័រដោយអង្គជំនុំជម្រះត្រឹម ៧៥០ ទំព័រ ហើយសហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតត្រឹម ៣៥០ ប៉ុណ្ណោះក្នុងការឆ្លើយតប[13]។

9. សហព្រះរាជអាជ្ញាបានអះអាងថា ការផ្ដល់ទំព័រចំនួន ១៤៥ បន្ថែម គឺជាការសមស្រប និងចាំបាច់ក្នុងការធានាភាពត្រឹមត្រូវយុត្តិធម៌ក្នុងការប្រព្រឹត្តទៅលើភាគីនានាចំពោះបណ្ដឹងសាទុក្ខ និងអាចឱ្យខ្លួនធ្វើការឆ្លើយតបបានពេញលេញ និងមានប្រសិទ្ធិភាពទៅលើការជំទាស់របស់ ខៀវ សំផន[14]។

*សារណាតបរបស់ ខៀវ សំផន*

---

[11] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៨។

[12] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩។

[13] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០។

[14] សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១។

10. ផ្អែកតាម ខៀវ សំផន បានឱ្យដឹងថា ឧបសម្ព័ន្ធ ក ពុំមានការជំទាស់បន្ថែមទេ និងបានកត់សម្គាល់ថា រាល់អំណះអំណាងផ្លូវច្បាប់ទាំងអស់ដែលសហព្រះរាជអាជ្ញាត្រូវឆ្លើយតប មាននៅក្នុងសារណាបណ្តឹងសាទុក្ខចំនួន ៧៥០ ទំព័រនោះ។ ខៀវ សំផន អះអាងថា ឧបសម្ព័ន្ធ ក មានតារាងសង្ខេបអំណះអំណាងនៃបណ្តឹងសាទុក្ខរបស់ខ្លួន និងបានភ្ជាប់ទំនាក់ទំនងសារណានេះទៅនឹងកំហុសដែលបានកំណត់អត្តសញ្ញាណនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដែលត្រូវបានរៀបចំដោយតាមបែបខុសៗគ្នា។ ខៀវ សំផន បានលើកឡើងថា ឧបសម្ព័ន្ធ ក ពុំមែន'សំខាន់ទាំងស្រុង' និងចាំបាច់ចំពោះសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ប៉ុន្តែត្រឹមតែជា"ត្រីវិស័យ"តម្រង់ទិសអ្នកអានសារណាចំនួន ៧៥០ ទំព័រ ជាមួយនឹងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[15]។

11. ខៀវ សំផន ក៏បានលើកឡើងផងដែរថា គោលបំណងនៃការបញ្ចូលអំណះអំណាងពីមុនៗតាមរយៈការយោង គឺដើម្បីជៀសវាងការលើកច្រំដែល និងបានអះអាងថា សហព្រះរាជអាជ្ញាអាចធ្វើដូចគ្នាបានផ្អែកតាមយុត្តិសាស្ត្រពីមុនរបស់អង្គជំនុំជម្រះ[16]។

12. ជាចុងក្រោយ ខៀវ សំផន បានអះអាងថា ការបន្ថែមទំព័រចំនួន ១៤៥ ដែលសហព្រះរាជអាជ្ញាស្នើសុំ បានបង្កការពន្យារពេលដោយឥតចាំបាច់លើកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ និងជាពិសេសបានពិចារណាទៅលើការពន្យារពេលសម្រាប់ការបកប្រែ ដែលកាលបរិច្ឆេទសម្រាប់ការដាក់សារណាតបនឹងត្រូវចាប់ផ្តើមគិតចាប់ពីពេលនោះតទៅ[17]។ អាស្រ័យហេតុនេះ ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះបដិសេធសំណើរបស់សហព្រះរាជអាជ្ញា។

*ការឆ្លើយតប*

13. សហព្រះរាជអាជ្ញាបានលើកឡើងថា ប្រសិនបើអង្គជំនុំជម្រះទទួលយកអំណះអំណាងរបស់ ខៀវ សំផន ដែលថា ឧបសម្ព័ន្ធ ក ពុំបានបន្ថែមអ្វីសំខាន់លើសារណាបណ្តឹងសាទុក្ខនោះ សំណើនេះគប្បីត្រូវ

---

[15] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៤ ដល់ ៥។

[16] *សូមមើល* សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៦ *យោង*សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមទំព័រ និងពេលវេលា ដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ៩៖ "*ទាក់ទងទៅនឹងអំណះអំណាងណាមួយរបស់ នួន ជា ឬ ខៀវ សំផន ដែលអាចត្រូវដាក់បញ្ចូលតាមរយៈការយោងទៅលើសារណាពីមុនៗ អង្គជំនុំជម្រះតុលាការកំពូលចាត់ទុកបញ្ហានេះជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីជៀសវាងភាពច្រំដែល ដែលមានអត្ថិភាពចំពោះសហព្រះរាជអាជ្ញាផងដែរ*"។

[17] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៧។

បដិសេធចោល។ ទោះបីជាយ៉ាងណាក្តី ជាជម្រើស ប្រសិនបើអង្គជំនុំជម្រះពិចារណាឃើញថា ឧបសម្ព័ន្ធ ក បានបន្ថែមខ្លឹមសារលើសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រ គប្បីត្រូវអនុញ្ញាត[18]។

14. សហព្រះរាជអាជ្ញាចាត់ទុកឧបសម្ព័ន្ធ ក គឺជាផែនទីប្រាប់ផ្លូវនៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលផ្តល់ការណែនាំ និងសេចក្តីបំភ្លឺទាក់ទងទៅនឹងខ្លឹមសារនៃសារណាបណ្តឹងសាទុក្ខនោះ និងមានសេចក្តីសង្ខេបនៃអំណះអំណាងដែល ខៀវ សំផន មានបំណងចង់លើកនៅក្នុងសារណា ប៉ុន្តែពុំបានធ្វើដូច្នេះដោយសារជៀសវាងការដាក់លើសចំនួនទំព័រកំណត់ត្រឹម ៧៥០ ទំព័រដែលអង្គជំនុំជម្រះអនុញ្ញាត។ សហព្រះរាជអាជ្ញាបានអះអាងថា ជម្រើសរបស់ ខៀវ សំផន មានអានុភាពប៉ះពាល់ជាអវិជ្ជមានដល់ភាគីជំទាស់បណ្តឹងសាទុក្ខនោះ និងអាចជួសជុលសងដោយការអនុញ្ញាតតាមសំណើសុំនេះ[19]។ ដើម្បីឱ្យស្មើភាព សហព្រះរាជអាជ្ញាស្នើសុំបន្ថែម ៣៥ ទំព័រសម្រាប់ឆ្លើយតបទៅនឹងឧបសម្ព័ន្ធ ក[20]។

15. បន្ថែមលើនេះ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា ខៀវ សំផន ធ្វើការសន្មតពុំត្រឹមត្រូវថា សហព្រះរាជអាជ្ញាអាចឆ្លើយតបបានទៅនឹងការបញ្ចូលសារណាពីមុនៗតាមរយៈការយោង នេះដូចអ្វីដែលខ្លួនធ្លាប់ធ្វើកន្លងមក ប៉ុន្តែ ដោយហេតុថា សារណាដែលបានធ្វើឡើងនៅមុនពេលសាលក្រមអង្គជំនុំជម្រះសាលាដំបូង គឺសម្រាប់មូលហេតុដែលខុសគ្នាពីបណ្តឹងសាទុក្ខបច្ចុប្បន្ន[21]។

16. សហព្រះរាជអាជ្ញាបានលើកឡើងថា ការជំទាស់របស់ ខៀវ សំផន ថា ការអនុញ្ញាតតាមសំណើនឹងបង្កឱ្យមានការពន្យារពេលឥតចាំបាច់នោះ ពុំមានមូលដ្ឋានគាំទ្រឡើយ ជាពិសេសដោយសារ ខៀវ សំផន ខកខានក្នុងការបង្ហាញថា សិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះឆាប់រហ័សនោះត្រូវបានរំលោភបំពាន យ៉ាងដូចម្តេច ឬថា ការពន្យារពេលនេះនឹងរារាំងកិច្ចដំណើរការនីតិវិធីដែលត្រូវបញ្ចប់ក្នុងរយៈពេលសមស្របនោះឡើយ[22]។

---

[18] ការឆ្លើតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២ ដល់ ៤។

[19] ការឆ្លើតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣ ដល់ ៤។

[20] ការឆ្លើតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥។

[21] ការឆ្លើតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦។

[22] ការឆ្លើតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩។

17. ជាសរុប សហព្រះរាជអាជ្ញាបានអះអាងថា ក្នុងការរឹតត្បិតសារណាតបមិនឱ្យលើកឡើងនៅពេលសវនាការផ្ទាល់មាត់ ជៀសពុំរួចអង្គជំនុំជម្រះត្រូវបាត់បង់ឱកាសក្នុងការវាយតម្លៃពេញលេញលើសារណាតបនីមួយៗនៅមុនពេលសវនាការផ្ទាល់មាត់ ហើយធ្វើឱ្យអង្គជំនុំជម្រះពុំទទួលបានអត្ថប្រយោជន៍ពីលទ្ធភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការពិនិត្យលើសារណារតបរបស់សហព្រះរាជអាជ្ញា ដើម្បីជៀសវាងការត្រួតគ្នា និងភាពច្រំដែល[23]។ ដូច្នេះ សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះអនុញ្ញាតសំណើនេះដើម្បីសម្រួលលទ្ធភាពរបស់ខ្លួនក្នុងការដាក់សារណាតបពេញលេញ ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន[24]។ សហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះឱ្យ i) បដិសេធឧបសម្ព័ន្ធ ក ឬអនុញ្ញាតបន្ថែម ៣៥ ទំព័រទៀតដើម្បីឆ្លើយតបលើបញ្ហានេះ និង ii) អនុញ្ញាត ១១០ ទំព័របន្ថែមទៀត ដើម្បីឆ្លើយតបដោយប្រសិទ្ធភាពទៅនឹងសារណាពីមុនៗដែលបានដាក់បញ្ចូលតាមរយៈការយោងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន[25]។

## គ. ច្បាប់ជាធរមាន

18. មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. ចែងថា អង្គជំនុំជម្រះពាក់ព័ន្ធ អាចតាមការស្នើសុំរបស់ភាគី បង្កើនចំនួនសន្លឹករបស់ឯកសារនៅក្នុងកាលៈទេសៈពិសេស។

## ឃ. ការពិភាក្សា

19. ជាសេចក្តីសង្កេតបឋម អង្គជំនុំជម្រះតុលាការកំពូលរំឭកថា ខៀវ សំផន បានដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួនជាភាសាបារាំង ហើយការបកប្រែជាភាសាខ្មែរ និងអង់គ្លេសដាក់តាមក្រោយ។ អង្គជំនុំជម្រះបច្ចុប្បន្នបានទទួលសំណើសុំរបស់សហព្រះរាជអាជ្ញា ខណៈដែលកំពុងរង់ចាំការបកប្រែផ្លូវការនៃសារណាបណ្តឹងសាទុក្ខនេះដោយអង្គភាពបកប្រែភាសា ("ITU")។ ទោះជាយ៉ាងណាក្តី ដើម្បីជាប្រយោជន៍នៃការពន្លឿននីតិវិធី និងភាពត្រឹមត្រូវយុត្តិធម៌ដល់ភាគីទាំងអស់ អង្គជំនុំជម្រះបានសំអាងលើការបកប្រែមិនផ្លូវការ ព្រមទាំងសារណារបស់ភាគីក្នុងការវិនិច្ឆ័យសំណើនេះ។ អង្គជំនុំជម្រះសង្ឃឹមថាភាគីបង្ហាញសារណារបស់ខ្លួនដោយពិតប្រាកដដែលឆ្លុះបញ្ចាំងការពិតនៃខ្លឹមសារនៅក្នុងឧបសម្ព័ន្ធ ក។

---

[23] ការឆ្លើតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១០។

[24] ការឆ្លើតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១១។

[25] ការឆ្លើតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១២។

(i) *ឧបសម្ព័ន្ធ ក*

20. ដោយសារភាគីទាំងពីរយល់ស្របទៅនឹងអត្ថប្រយោជន៍នៃឧបសម្ព័ន្ធ ក ដែលជាត្រីវិស័យ ឬផែនទីបង្ហាញផ្លូវ ដែលជួយសម្រួលដល់ការអានសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដូច្នេះគ្មានប្រយោជន៍អ្វីដែលត្រូវបោះបង់ឧបសម្ព័ន្ធ ក នេះចោលនោះទេ។ ដោយសារសហព្រះរាជអាជ្ញាទំនងជាពុំជំទាស់ទៅនឹងអង្គជំនុំជម្រះក្នុងការទទួលយកសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ទាំងមូល អាស្រ័យហេតុនេះ អង្គជំនុំជម្រះទទួលយកសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែម ៣៥ ទំព័រ ដើម្បីដោះស្រាយបញ្ហានានាដែលមាននៅក្នុងឧបសម្ព័ន្ធ ក។

(ii) *សារណាពីមុនៗដែលបានដាក់បញ្ចូលតាមរយៈការយោង*

21. ទាក់ទងទៅនឹងការបញ្ចូលតាមរយៈការយោងនូវសារណាពីមុនៗចំនួន ២៣៦ ទំព័រចេញពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ក្នុងសំណុំរឿង ០០២/០១ និង សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះយល់ស្របថា នេះគឺជាវិធីសាស្ត្រក្នុងការជៀសវាងភាពច្រំដែល។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សារណាដែលបង្ហាញនៅមុខអង្គជំនុំជម្រះសាលាដំបូងតាមរបៀបដូចគ្នាក្នុងរឿងក្តីនេះ ត្រូវបានបដិសេធចោល ដោយមូលហេតុថា *វិធីសាស្ត្របែបនេះ គឺជាការប៉ុនប៉ងដែលពុំត្រូវបានអនុញ្ញាត ដើម្បីគេចវេសពីការកំណត់ចំនួនទំព័រដោយអង្គជំនុំជម្រះលើសារណារបស់ភាគីនីមួយៗ*[26]។ អង្គជំនុំជម្រះសង្កត់ធ្ងន់ថា ការទទួលយកសារណាដែលមានឧបសម្ព័ន្ធ តាមន័យប្រយោល គឺជាការទទួលយកនូវអ្វីដែលពាក់ព័ន្ធ និងការទទួលយកតាមទម្រង់នូវទឡ្ហីករណ៍ដែលបានលើកឡើង។

22. ទាក់ទងទៅនឹងសំណើសុំចំពោះមុខ អង្គជំនុំជម្រះពុំជឿជាក់ថា សហព្រះរាជអាជ្ញាចាំបាច់ត្រូវឆ្លើយតបតាមវិធីសាស្ត្រដូចគ្នាតាមរយៈការយោងទៅលើសារណាមុនៗឡើយ។ សារណាប្រភេទនេះភ្ជាប់ការយល់ឃើញ និងភស្តុតាងពាក់ព័ន្ធទៅនឹងការជំនុំជម្រះ ឬអង្គជំនុំជម្រះសាលាដំបូងមួយផ្សេងនៅមុនពេលចេញសាលក្រមរបស់ខ្លួនក្នុងសំណុំរឿងដែលរងបណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាថា កាលៈទេសៈដែលសារណាត្រូវបានបង្កើតឡើងមុនពេលសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ អាចខុសពីកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នជាក់ស្តែង និងជាលទ្ធផលយល់ឃើញថា សារណាតបមិនមែនជានិច្ចកាលអាចត្រូវបានដោះស្រាយប្រកបដោយអត្ថន័យតាមរយៈត្រឹមតែការយោងធម្មតាទៅលើសារណាពីមុនៗនោះទេ។

---

[26] សាលក្រមអង្គជំនុំជម្រះសាលាដំបូង ឯកសារលេខ E465 កថាខណ្ឌ ៣៧០៥។

23. អាស្រ័យហេតុនេះ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែម ១១០ ទំព័រ ជាពិសេសសម្រាប់ឆ្លើយតបទៅនឹងសារណាមុនៗចំនួន ២៣៦ ទំព័រដែលបានដាក់ចូលតាមរយៈការយោងក្នុងសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន។

iii) *អំណះអំណាងពាក់ព័ន្ធទៅនឹងការពន្យារពេលឥតចាំបាច់*

24. ខៀវ សំផន បានលើកឡើងថា ការផ្ដល់តាមសំណើសុំរបស់សហព្រះរាជអាជ្ញា អាចនឹងពន្យារពេលកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខដោយឥតចាំបាច់ ដោយហេតុថា នឹងមានការពន្យារពេលដល់ការបកប្រែ[27]។ អង្គជំនុំជម្រះសង្កេតឃើញថា ពុំមានព័ត៌មានបង្ហាញថា សិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ នឹងត្រូវទទួលរងការប៉ះពាល់ជាអវិជ្ជមានឡើយ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចបដិសេធអំណះអំណាងនេះរបស់ ខៀវ សំផន ដោយសារពុំមានមូលដ្ឋានគាំទ្រ។

iv) *សេចក្ដីសន្និដ្ឋាន*

25. អង្គជំនុំជម្រះពិចារណាឃើញថា ការដាក់បញ្ចូលឧបសម្ព័ន្ធ ក ដែលមាន ៧៦ ទំព័រដែលភាគីទាំងពីរយល់ស្របនេះ គឺមានអត្ថប្រយោជន៍ បូករួមទាំងសារណាពីមុនៗយ៉ាងតិចចំនួន ២៣៦ ទំព័រ ដែលបានពង្រីកលើការជំនុំជម្រះចំនួនពីរ គឺជាកាលៈទេសៈពិសេសដូចមានចែងក្នុងមាត្រា ៥.៤ នៃសេចក្ដីណែនាំអនុវត្ត និងដូច្នេះ អង្គជំនុំជម្រះចាត់ទុកថា ជាការសមស្របក្នុងការផ្ដល់តាមសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែម ១៤៥ ទំព័រ ដើម្បីអាចឆ្លើយតបបានយ៉ាងមានប្រសិទ្ធភាពទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន។

[27] សារណាតបរបស់ ខៀវ សំផន កថាខណ្ឌ ៧។

## ខ. ផ្នែកសម្រេចសេចក្តី

26. យោងតាមសម្អាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ**

**អនុញ្ញាត**តាមសំណើរបស់សហព្រះរាជអាជ្ញាសុំៈ

(i) បន្ថែមចំនួន ៣៥ ទំព័រដើម្បីឆ្លើយតបទៅនឹងឧបសម្ព័ន្ធ ក និង

(ii) បន្ថែមចំនួន ១១០ ទំព័រ ដើម្បីឆ្លើយតបទៅនឹងសារណាពីមុនៗដែលបានដាក់បញ្ចូលតាមរយៈការយោងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០២០

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រិម**